ទីស្តីការក្រសួងយុត្តិធម៌

លេខ ០៥ សរច-៩៤

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## សារាចរ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ផ្ញើចំពោះ

លោកប្រធាតុលាការ គ្រប់ខេត្ត ក្រុង

លោកព្រះរាជអាជ្ញាអមតុលាការគ្រប់ខេត្ត ក្រុង

**សូមជ្រាប។**

**កម្មវត្ថុ:** សេចក្តីណែនាំអំពីការចោទប្រកាន់ជនល្មើសពីបទសមគំនិត និងអំណាចនៃការចេញដីកាចាប់ខ្លួន ។

ខ្ញុំសូមជម្រាបលោកថាក្រោយពីបានពិនិត្យនូវរបាយការណ៍ និងស្ថិតិប្រចាំខែរបស់តុលាការនិងអយ្យការគ្រប់ខេត្ត-ក្រុង ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញមានចំណុច២សំខាន់ ដែលត្រូវអស់លោកយកចិត្តទុកដាក់អនុវត្តអោយបានត្រឹមត្រូវតាមច្បាប់ ៖

**១-ការចោទប្រកាន់ជនសមគំនិត**

-តាមគោលការណ៍ ក្នុងបទល្មើសមួយអាចធ្វើការចោទប្រកាន់ជនសមគំនិតបាន លុះត្រាតែមានការចោទប្រកាន់ជនល្មើសដៃដល់ជាមុន ទោះបីជាក្នុងករណីជនល្មើសដៃដល់នោះត្រូវស្លាប់ រត់គេចខ្លួនបាត់ គ្មានសាវតារជាតិ ជាអនីតិជន ជាជនវិកលចរិត ដោយច្បាប់ទទួលស្គាល់បុព្វសិទ្ធិ ជាធម្មជាតិ ឬដោយច្បាប់ក៏ដោយ ក៏ត្រូវមានចុះឈ្មោះសម្គាល់ជនល្មើសដៃដល់នេះមុនឈ្មោះជនល្មើសសមគំនិត ដែលត្រូវទទួលខុសត្រូវជាបទអាជ្ញាជាដរាប ពីព្រោះក្នុងគ្រប់បទអាជ្ញាពុំត្រូវចោទប្រកាន់ជនសមគំនិតដោយពុំបានចោទប្រកាន់ជនល្មើសដៃដល់ឡើយ ។

**២-អំណាចនៃការចេញដីកាចាប់ខ្លួន**

សំណុំរឿងព្រហ្មទណ្ឌមួយក្នុងចំណាត់ការ ដែលអយ្យការកំពុងធ្វើការស៊ើបអង្កេតបឋមតាមនីតិវិធីនៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០-៩-៩២ នឹងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ២១ ក្រ ចុះថ្ងៃទី០៨-០៣-៩៣ ព្រះរាជអាជ្ញាពុំមានសិទ្ធិចេញដីកាចាប់ខ្លួនមនុស្សត្រូវចោទទេ លើកលែងតែករណីបទល្មើសជាក់ស្តែងលោកធ្វើការពិនិត្យបទល្មើសនៅនឹងទីកន្លែងប្រព្រឹត្តបទល្មើស ហើយជនល្មើសត្រូវបានឃាត់ខ្លួននោះទើបលោកអាចចោទប្រកាន់បញ្ជូនជនល្មើសនេះជំនុំជម្រះផ្តល់តាមនីតិវិធី ដើម្បីសុំឱ្យចៅក្រមជំនុំជម្រះកាត់ទោសតាមច្បាប់ ។ ក្នុងករណីនេះ បើចៅក្រមជំនុំជម្រះមិនអាចដាក់ជំនុំជម្រះបានភ្លាមៗទេនោះ ចៅក្រមជំនុំជម្រះត្រូវសម្រេចអំពីការឃុំខ្លួន អនុញ្ញាតអោយនៅក្រៅឃុំជាបណ្តោះអាសន្នសិនប្រសិនបើទោសដែលមានចែងក្នុងបទល្មើសដែលជននោះបានប្រព្រឹត្តមានកំណត់ទណ្ឌកម្មដាក់ពន្ធនាគារលើសពី១ឆ្នាំ លោកព្រះរាជាអាជ្ញាត្រូវតែធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងទៅចៅក្រមស៊ើបអង្កេត ដើម្បីចៅក្រមស៊ើបអង្កេតពិនិត្យ និងសម្រេចអំពីការឃុំខ្លួនឬអនុញ្ញាតអោយនៅក្រៅឃុំបណ្តោះអាសន្ន ។

សូមលោកពិនិត្យអំពីចំណាត់ការរបស់អស់លោកឡើងវិញ ហើយអនុវត្តតាមសេចក្តីណែនាំខាងលើនេះឲ្យបានត្រឹមត្រូវ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ១៩៩៤

**រដ្ឋលេខាធិការ**

............**ទីឆុង**

<u>ចម្លងជូន</u>

-តុលាការកំពូល

-មហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍

-មហាអយ្យការអមសាលាឧទ្ធរណ៍

-ប្រធានតុលាការយោធា

-ព្រះរាជអាជ្ញាអមតុលាការយោធា

-ដើម្បីជូនជ្រាប និងអនុវត្ត